# មហាគរុវិទូ៖ លោក ហ្ជន ឌូវី និងលោកស្រី ហ្សែន អាដាំស៍

## (JOHN DEWEY AND JANE ADDAMS)

*ដោយ៖* **បណ្ឌិត សូ សុធីរ**
*មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

### សេចក្តីផ្តើម

*លោក ហ្ជន ឌូវី (១៨៥៩-១៩៥២) គឺជាទស្សនវិទូ ចិត្តវិទូ និងជាអ្នកកែទម្រង់អប់រំជនជាតិអាម៉េរិកដ៏លេចធ្លោម្នាក់។ គាត់គឺជាឥស្សរជនសំខាន់ក្នុងការអភិវឌ្ឍនៃប្រតិបត្តិនិយម ជាគោលវិធីទស្សនវិជ្ជា ដែលសង្កត់ធ្ងន់លើការអនុវត្តជាក់ស្តែងនៃគំនិត និងសារៈសំខាន់នៃបទពិសោធ។*

*ស្នាដៃរបស់លោកឌូវី មានឥទ្ធិពលយ៉ាងខ្លាំងទៅលើការអប់រំ។ លោកជឿជាក់ថា ការអប់រំគួរតែជាដំណើរការបន្តនៃការរីកចម្រើន និងការអភិវឌ្ឍ ហើយការរៀនសូត្រគួរមានសកម្មភាព និងបទពិសោធ។ គាត់បានតស៊ូមតិ សម្រាប់គោលវិធីផ្តោតលើកុមារចំពោះការអប់រំ ដែលកុមារត្រូវបានលើកទឹកចិត្តឱ្យឈ្វេងយល់ តាមរយៈសកម្មភាពដោយដៃ និងការដោះស្រាយបញ្ហា។*

*គំនិតរបស់លោក ឌូវី លើការអប់រំមានឥទ្ធិពលយូរអង្វែងលើការអនុវត្តការអប់រំនៅទូទាំងពិភពលោក។ ការសង្កត់ធ្ងន់របស់គាត់លើការគិតបែបរិះគិត ការដោះស្រាយបញ្ហា និងទំនួលខុសត្រូវសង្គម បន្តបង្កើតវិធីដែលទាក់ទងយ៉ាងជិតស្និតនឹងការបង្រៀន និងការរៀន។*

### ១-លោក ហ្ជន ឌូវី៖ ការសិក្សាតាមបទពិសោធ

#### ក-សាលារៀននិងសង្គម និងសាលារៀនដែលជាមន្ទីរពិសោធន៍

*លោក ឌូវី (១៨៥៩-១៩៥២) គឺជាទស្សនវិទូអាម៉េរិកម្នាក់ដ៏សំខាន់បំផុត[1]។ គាត់បានអភិវឌ្ឍទស្សនវិជ្ជាអប់រំបែបពិសោធនិយមមុនគេ ប្រឆាំងនឹងរាំងននក្រោយឆាកនៃការផ្លាស់ប្តូរផ្នែកសង្គម នយោបាយ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដែលបានកើតឡើង នៅសហ*

[1] For a biography of Dewey, see Jay Martin, *The Education of John Dewey: A Biography* (New York: Columbia University Press, 2002); for a commentary on Dewey, see Walter Feinberg, “Dewey and Democracy: At the Dawn of the Twenty-first Century,” *Educational Theory* (Spring 1993), pp. 195-216.

*រដ្ឋអាម៉េរិក នៅពាក់កណ្ដាលទី១នៃស.វ.ទី២០[2]។ ចលនាកំណែទម្រង់បែបអភិវឌ្ឍខាងនយោបាយ បានក្រោចការគិតរបស់គាត់ ហើយគាត់បានស្វែងរក ដើម្បីរាប់បញ្ចូលបញ្ញត្តិនៃចរន្តសច្ចភាពមិនស្ថិតស្ថេរខាងវិទ្យាសាស្ត្រ ទៅជាទស្សនវិជ្ជារបស់គាត់។ ចូរយល់ដឹងដោយវាងវៃនៃអំណាចបច្ចេកវិទ្យា ដើម្បីប្រែជាតុសង្គម។ លោក ឌូវី ចង់ឱ្យគេប្រើវា ដើម្បីគោលបំណងប្រជាធិបតេយ្យ។ គាត់បានមើលឃើញការអប់រំ ថាជាឧបករណ៍មួយ ដើម្បីអភិវឌ្ឍសង្គម ហើយបានមើលឃើញសាលារៀន មានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងសង្គម។ នៅពេលដែលធ្វើជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យឈីកាហ្គោ ផ្នែកមន្ទីរពិសោធន៍ពីឆ្នាំ១៨៩៦-១៩០៤ គាត់ បានសាកល្បងទស្សនវិជ្ជាអប់រំប្រតិបត្តិនិយមរបស់គាត់ ដោយបានប្រើប្រាស់វាជាមូលដ្ឋានគ្រឹះ សម្រាប់សកម្មភាព និងគម្រោងការសិក្សារបស់កុមារ។*

**ខ-ការប្រឈមមុខនឹងបញ្ហាគោលការណ៍នៃការបង្រៀន និងរៀន**

*សៀវភៅរបស់លោក ឌូវី ដែលមានចំណងជើងថា កុមារ និងកម្មវិធីសិក្សា* (The Child and the Curriculum) *បានផ្ដល់នូវមគ្គុទ្ទេសន៍ដល់គោលការណ៍ និងការប្រតិបត្តិ ដែលត្រូវបានប្រើប្រាស់ នៅមន្ទីរពិសោធន៍សាកលវិទ្យាល័យឈីកាហ្គោ។ កុមារ ត្រូវបានគេមើលឃើញថាជាមនុស្សសកម្មក្នុងសង្គម ដែលចង់ចេះដឹង ដើម្បីស្វែងរក និងទទួលបានការគ្រប់គ្រងទៅលើបរិស្ថាន។ តាមការធ្វើអន្តរកម្មជាមួយពិភពលោក សិស្ស ត្រូវប្រឈមមុខទាំងបញ្ហាសង្គម និងបុគ្គល។ ការជួបប្រទះបញ្ហាបែបនេះ ក្រោចកុមារឱ្យចេះប្រើប្រាស់បញ្ញារបស់ពួកគេ ដើម្បីដោះស្រាយភាពពិបាក ហើយនិងចំណេះដឹងរបស់ពួកគេ តាមរបៀបមួយជាឧបករណ៍ និងសកម្មភាព[3]។*

**គ-ជំហានក្នុងការសិក្សា តាមវិធីវិទ្យាសាស្ត្រ**

*ចំពោះលោកឌូវី វិធីវិទ្យាសាស្ត្រ គឺជាលំនាំដ៏មានប្រសិទ្ធភាពបំផុត ដែលយើងមានដើម្បីដោះស្រាយបញ្ហា។ នៅពេលដែលគេប្រើប្រាស់វិធីវិទ្យាសាស្ត្រ ដើម្បីដោះស្រាយបញ្ហានោះ កុមារសិក្សាពីរបៀបគិតដោយប្រសិទ្ធភាព និងដើម្បីដឹកនាំការពិ សោធរបស់គេ តាមរបៀបដែលនាំទៅដល់ការលូតលាស់បុគ្គល និងសង្គម។ ជំហានដូចតទៅ មានសារៈសំខាន់ បំផុតក្នុងការអនុវត្តវិធីវិទ្យាសាស្ត្ររបស់លោក ឌូវី ដើម្បីបង្រៀន និងរៀន៖*

[2] For Dewey’s relationship to the development of pragmatism, see Louis Menard, *The Metaphysical Club: The Story of Ideas in America* (New York: Farrar, Straus and Girous 2001).

[3] For an analysis of Dewey’s democratic approach to education, see Sandra Rosenthal,” Democracy and Education: A Deweyan Approach,” *Educational Theory* (Fall 1993), pp. 377-389.

១-សិស្សមានការពាក់ព័ន្ធនឹងបទពិសោធជាក់ស្តែង (A genuine Experience) ដែលធ្វើឱ្យគេចាប់អារម្មណ៍ពិតប្រាកដ។

២-ជាមួយបទពិសោធទាំងនេះ សិស្សមានបញ្ហាជាក់ស្តែង ដែលភ្ញោចការគិត។

៣-សិស្សទទួលបានព័ត៌មានដែលត្រូវការដើម្បីដោះស្រាយបញ្ហា។

៤-សិស្សរៀបចំដំណោះស្រាយសាកល្បង និងអាចធ្វើទៅបាន ដែលអាចដោះស្រាយបញ្ហា។

៥-សិស្សធ្វើការសាកល្បងដំណោះស្រាយទាំងឡាយ តាមការអនុវត្តវា ចំពោះបញ្ហា។ តាមរបៀបនោះ សិស្សស្ថាបនា និងធ្វើឱ្យមានសុពលភាពចំណេះដឹងរបស់គេ[4]។

**ឃ-ការកសាងចំណេះដឹង ដើម្បីដោះស្រាយបញ្ហា**

លោក ឌូវី មើលឃើញចំណេះដឹង មិនគ្រាន់តែជាព័ត៌មាននិចលទេ ប៉ុន្តែ ថែមទាំងជាឧបករណ៍ដើម្បីដោះស្រាយបញ្ហាទៀតផង។ យើងប្រើប្រាស់ចំណេះដឹង ដែលមនុស្សយើងបានរក្សាទុកដូចជាគំនិតអតីតកាល របកគំហើញ និងការបង្កើតថ្មី ដើម្បីរៀបចំដំណោះស្រាយ តាមបែបសម្មតិកម្ម ចំពោះបញ្ហាបច្ចុប្បន្ន ហើយបន្ទាប់មកធ្វើការសាកល្បង និងកសាងចំណេះដឹងឡើងវិញ តាមពន្លឺនៃតម្រូវការបច្ចុប្បន្ន។ ពីព្រោះមនុស្ស និងបរិស្ថានរបស់គេ ផ្លាស់ប្តូរជាប្រចាំ ចំណេះដឹងក៏ត្រូវបានរៀបចំ ឬស្ថាបនាឡើងវិញជាបន្តបន្ទាប់ផងដែរ។ នៅពេលដែលបញ្ហាមួយ ត្រូវបានគេដោះស្រាយនោះ ដំណោះស្រាយរបស់វា ត្រូវបានបញ្ចូលទៅជាចំណេះដឹងដែលគេរក្សាទុក។

**ខ-ការអប់រំ សម្រាប់ការលូតលាស់សង្គម និងបុគ្គល**

**ការអប់រំ និងការសិក្សា** លោក ឌូវី បានចាត់ទុកការអប់រំ ថាជាលំនាំសង្គមមួយ ដែល តាមលំនាំនោះ សមាជិកក្មេងខ្ចីរបស់ក្រុម ជាពិសេសកុមារ សិក្សាដើម្បីចូលរួមក្នុងជីវិតក្រុម។ តាមរយៈការអប់រំ កុមារ ត្រូវបានសិក្សាស្គាល់នូវមត៌កវប្បធម៌ និងសិក្សា ដើម្បីប្រើប្រាស់វាក្នុង ដំណោះស្រាយបញ្ហា។ គោលបំណងតែមួយរបស់ការអប់រំ គឺត្រូវរួមចំណែកដល់ការលូតលាស់ជាបុគ្គល និងសង្គម។ ដូចដែលលោកឌូវី បានរៀបរាប់ដូច្នេះដែរ ការអប់រំគឺជាការស្ថាបនាឡើងវិញ ឬជាការរៀបចំឡើងវិញនៃបទពិសោធ ដែលបន្ថែមទៅឱ្យអត្ថន័យនៃបទពិសោធ និងដែលបង្កើនបំណិន ដើម្បីដឹកនាំបទពិសោធជាបន្តបន្ទាប់។

**ច-កម្រិតទាំង៣នៃកម្មវិធីសិក្សា**

កម្មវិធីសិក្សារបស់លោកឌូវី រួមមានសកម្មភាព និងលំនាំសិក្សាចំនួន៣កម្រិត៖

[4] John Dewy, *Democracy and Education* (New York: Macmillan, 1916), p. 192.

១-កម្រិតទី១ គឺកម្រិតសកម្មភាព ធ្វើឱ្យកុមារចូលរួមក្នុងគម្រោងការ ដែលក្នុងនោះ គេស្រាវជ្រាវរុករកក្នុងបរិស្ថាន និងរៀប ចំគំនិតរបស់គេ ទៅជាទម្រង់រូបី។ សកម្មភាពដំបូងទាំងនេះ បានអភិវឌ្ឍបំណិនចលករ និងសរីរាង្គឥន្ទ្រិយ និងលើកទឹកចិត្ត ដល់សង្គមូបនីយកម្មតាមរយៈគម្រោងសហការក្នុងក្រុម។

២-កម្រិតទី២ ពង្រីកបញ្ញត្តិនៃកាល និងលំហសិស្ស តាមរយៈគម្រោងការ ដែលជាប់ពាក់ព័ន្ធពួកគេខាងប្រវត្តិវិទ្យា និងភូមិវិទ្យា។

៣-កម្រិតទី៣ គឺវិទ្យាសាស្ត្រ បាននាំឱ្យសិស្ស មានទំនាក់ទំនងនឹងមុខវិជ្ជាផ្សេងៗ ដូចជា ជីវវិទ្យា គីមីវិទ្យា និងវិទ្យាសាស្ត្រសង្គម ដែលពួកគេអាចប្រើប្រាស់ជាប្រភពព័ត៌មាន ដើម្បីដោះស្រាយបញ្ហា។

កម្រិតកម្មវិសិក្សាទាំង៣នេះ ធ្វើឱ្យការសិក្សា មានចលនាពីពលវេគសាមញ្ញ ទៅដល់ការសង្កេតបរិស្ថានដោយយកចិត្តទុក ដាក់ដើម្បីធ្វើផែនការសកម្មភាព ហើយជាចុងបញ្ចប់ ដើម្បីឆ្លុះបញ្ចាំង និងធ្វើតេស្តទៅលើផលនៃសកម្មភាព។

**ឆ-សាលារៀន គួរតែមានសេរីភាព និងប្រជាធិបតេយ្យ**

ក្នុងនាមជាអ្នកគាំទ្រការអប់រំ និងការសិក្សាតាមប្រជាធិបតេយ្យ លោក ឌូវី ចង់ឱ្យសាលា រៀនធ្វើជាបរិស្ថានប្រកបដោយសេរីភាព ដែលក្នុងនោះ សិស្សមានសេរីភាព ដើម្បីធ្វើការសាកល្បងគំនិតទាំងអស់ ជំនឿ និងតម្លៃ។ ក្នុងនាមជាស្ថាប័នប្រកបដោយប្រជាធិបតេយ្យ សាលារៀនគួរតែបើកចំហ និងប្រើប្រាស់ដោយមនុស្សទាំងអស់គ្នា។ ដោយប្រឆាំងទៅនឹងការបំបែកមនុស្សដោយឡែកពីគ្នា ដោយសារតែដើមកំណើតជាតិសាសន៍ សមធម៌ភេទ ឬវណ្ណៈសេដ្ឋកិច្ចនោះ លោក ឌូវី ជឿជាក់ថា សហគមន៍ ត្រូវធ្វើឱ្យមានឡើង នៅពេលដែលមនុស្ស បានបែងចែកបទពិសោធរបស់គេ ដើម្បីដោះស្រាយបញ្ហារួមទាំងឡាយ។

**ជ-ឥទ្ធិពលនៅលើការអភិវឌ្ឍនិយម**

**ឥទ្ធិលនៅលើការប្រតិបត្តិការអប់រំបច្ចុប្បន្ន** លោកឌូវី បានប្រើប្រាស់ឥទ្ធិពលដ៏ធំធេង ទៅលើការអប់រំអាម៉េរិក។ ដោយអនុវត្តប្រតិបត្តិនិយម ចំពោះការអប់រំ គាត់បានជួយបើកចំហ ការសិក្សាឱ្យមានការផ្លាស់ប្តូរ និងនវានុវត្តន៍។ គំនិតរបស់លោកឌូវី អំពីការពង្រីកក្នុងសង្គមនូវ បទពិសោធកុមារ ដែលត្រូវបានក្រោចដោយការអប់រំតាមបែបអភិវឌ្ឍដោយសង្កត់ធ្ងន់ទៅលើ ចំណូលចិត្ត និងតម្រូវការកុមារ។ សព្វថ្ងៃនេះ គរុវិទូ ដែលមានការពាក់ព័ន្ធការសិក្សា ទៅនឹងគោលបំណងសង្គមជាញឹកញាប់ធ្វើតាមបញ្ញត្តិអប់រំដែលបានត្រួសត្រាយដោយលោកឌូវី[5]។

[5] For analyses of Dewey's work in educational philosophy, see Matt Parmental,''The Structure of Dewey's Scientific Ethics''; and Eric Bredo, ''Understanding Dewey's Ethics,'' in *Philosophy of Education* (Urbana: Philosophy of Education Society/University of Illinois at Urbana-Champaign,2000), pp.143-154.

ឥទ្ធិពលរបស់ លោក ឌូវី ក៏ត្រូវអាចគេមើលឃើញផងដែរក្នុងការបង្រៀន ដែលនាំទៅ ដល់គោលវិធីតាមលំនាំតម្រង់ទិស ឬការប្រតិបត្តិ។

ឧទាហរណ៍ គោលវិធីភាសាពេញលេញ ដោយមានការសង្កត់ធ្ងន់ទៅលើសិល្បៈការ បង្រៀនភាសា តាមបរិស្ថានអប់រំទាំងមូល គឺជាការអភិវឌ្ឍថ្មីៗនេះ ដែលបែកចេញពីទស្សនវិជ្ជាបែបពិសោធននិយម ដែលជាមែកធាង បានត្រួសត្រាយដោយលោកឌូវី។

ជារួមមក ចំពោះលោកឌូវី មានទស្សនថា ការអប់រំគួរតែមានភាពថាមវន្ត ប្រជាធិបតេយ្យ និងបទពិសោធ ដោយផ្តោតលើការអភិវឌ្ឍទាំងមូលរបស់បុគ្គល និងការចូលរួមយ៉ាងសកម្មរបស់ពួកគេនៅក្នុងសង្គម។ ការរួមបញ្ចូលទ្រឹស្តីនិងការអនុវត្ត ចំណុចសំខាន់នៃបទពិសោធរបស់អ្នកសិក្សា និងតួនាទីនៃការអប់រំក្នុងការជំរុញពិភពលោក ដែលមានសមធម៌និងប្រជាធិបតេយ្យកាន់តែច្រើន។ ឥទ្ធិពលយ៉ាងជ្រាលជ្រៅដល់ការអនុវត្តអប់រំទំនើប ជាពិសេស នៅក្នុងគំរូសិក្សារីកចម្រើននិងបទពិសោធ។

## ២-លោកស្រី ហ្វៃន អាដាំស៍៖ ការអប់រំតាមបែបសង្គមូបនីយកម្ម

លោកស្រី ហ្វែនអាដាំស៍ (១៨៦០-១៩៣៥, ជនជាតិអាមេរិក) គឺជាអ្នកត្រួសត្រាយផ្លូវកំណែទម្រង់សង្គម សកម្មជន និងជាអ្នកដឹកនាំនៅក្នុងចលនាផ្ទះតាំងទីលំនៅ។ នាងត្រូវបានគេស្គាល់ថាជាអ្នកបង្កើតសាលារៀនហ៊ុលហៅស៍ នៅទីក្រុងឈីកាហ្គោ (Chicago) រដ្ឋអ៊ីលីណយស៍ (Illinois) ដែលជាលំនៅដ្ឋានដ៏ល្បីល្បាញបំផុតមួយ នៅក្នុងប្រវត្តិសាស្ត្រអាម៉េរិក។

សាលារៀនហ៊ុលហៅស៍ បានផ្តល់សេវាកម្មជាច្រើនដល់គ្រួសារក្រីក្រ ដែលភាគច្រើនជាជនអន្តោប្រវេសន៍ រួមទាំងការអប់រំ ការថែទាំសុខភាព ការថែទាំកុមារ និងជំនួយផ្នែកច្បាប់។ ការងាររបស់លោកស្រីអាដាំស៍ នៅឯសាលារៀនហ៊ុលហៅស៍ គឺមានភាពល្បីល្បាញ និងគាត់បានក្លាយជាសំឡេងនាំមុខគេសម្រាប់យុត្តិធម៌សង្គម និងកំណែទម្រង់។

លោកស្រី អាដាំស៍ គឺជាអ្នកតស៊ូមតិមិនចេះនឿយហត់ សម្រាប់ការបោះឆ្នោតរបស់ស្ត្រី សន្តិភាព និងយុត្តិធម៌សង្គម។ គាត់បានទទួលរង្វាន់ណូបែលសន្តិភាពក្នុងឆ្នាំ១៩៣១ សម្រាប់ការងាររបស់គាត់ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ និងសន្តិភាព។ កេរដំណែលរបស់គាត់នៅតែបន្តជំរុញ និងមានឥទ្ធិពលលើសកម្មជនសង្គម និងអ្នកកំណែទម្រង់នៅជុំវិញពិភពលោក។

លោកស្រី អាដាំស៍ ដែលជាស្ថាបនិកនៃសាលារៀនហ៊ុលហៅស៍ និងជាកិត្តិជនដែលបានត្រួសត្រាយខាងការងារសង្គម និងសិទ្ធិស្ត្រីនោះ បានអភិវឌ្ឍទ្រឹស្តីអប់រំ ដែលត្រូវបានគេហៅថា ការអប់រំតាមបែបសង្គមនីយក

*ម្ន។ ទស្សនវិជ្ជាអប់រំរបស់គាត់ បានសង្កត់ធ្ងន់ទៅលើការអប់រំជនអន្តោប្រវេសន៍តំបន់ជាយក្រុង និងស្ត្រី ហើយជារៀមច្បងនៃការអប់រំស្ត្រី និងពហុវប្បធម៌ទំនើប។*

### ក- សាលារៀនហ៊ុលហោស៍

*លោកស្រី,អាដាំស៍ បានបង្កើតសាលារៀនហ៊ុលហោស៍ នៅឈីកាហ្គោ ជិតតំបន់ជាយក្រុងប៉ែកខាងលិច នៅឆ្នាំ១៨៨៩ ក្នុងសង្កាត់ដែលមានជនអន្តោប្រវេសន៍ពហុវប្បធម៌ទើបមកដល់ថ្មីៗ។ លោកស្រី អាដាំស៍ និងសហការីរបស់គាត់ ដែលជាក្រុមបង្ហាត់ស្ត្រីក្មេងៗវណ្ណៈកណ្ដាលនោះ បានអប់រំជនអន្តោប្រវេសន៍ ហើយបន្តិចម្ដងៗ ត្រូវបានអប់រំដោយពួកគេផងដែរ។ សាលារៀនហ៊ុលហោស៍ បានផ្ដល់ទីកន្លែង ដែលជនអន្តោប្រវេសន៍ សិក្សាពីរបៀបស្វែងរកការងារ ទទួលបានប្រាក់ខែ ស្វែងរកការថែទាំសុខភាព និង អប់រំកូនៗរបស់ពួកគេ[6]។*

### ខ-អ្នកគាំទ្រពហុវប្បធម៌និយម

***គោលការណ៍នៃការបង្រៀន និងរៀនៈ***

*លោកស្រីអាដាំស៍ បានជឿជាក់ថា ជាយក្រុងការូបនីយកម្ម ឧស្សាហូបនីយកម្ម និងបច្ចេកវិទ្យា បានបញ្ចេញសមត្ថភាព និងពង្រីកអត្ថន័យ និងគោលបំណងនៃការអប់រំ។ មុខរបរ និងវិជ្ជាជីវៈទំនើប ត្រូវការទំនាក់ទំនងដោយប្រុងប្រយ័ត្ន ដល់សុកនិច្ច័យនៃគោលបំណងសង្គម និងទំនាក់ទំនងសង្គម ដែលចាំបាច់បង្កើតឡើងវិញ នូវសហគមន៍ប្រជាធិបតេយ្យពិតប្រាកដ[7]។*

*ក្នុងនាមជាអ្នកគាំទ្រពហុវប្បធម៌ដំបូងគេ លោកស្រីអាដាំស៍ បានស្វែងរក ដើម្បីបង្កើតទំនាក់ទំនង រវាងជនអន្តោប្រវេសន៍ថ្មីៗ និងសង្គមអាម៉េរិកទូលំទូលាយជាងមុនៗ គាត់ជឿជាក់ថា មានភាពខុសគ្នាខាងវប្បធម៌។ លោកស្រីអាដាំស៍ ចង់ឱ្យសាលារៀនសាធារណៈ មានបញ្ចូលមុខវិជ្ជា ប្រវត្តិវិទ្យា ទំនៀមទម្លាប់ ចម្រៀង បំណិនក្នុងការរកស៊ី និងរឿងនិទាននៃក្រុមជាតិសាសន៍ និងក្រុមជនជាតិភាគតិចក្នុងកម្មវិធីសិក្សា[8]។*

*លោកស្រីអាដាំស៍ ក្នុងនាមជាអ្នកគាំទ្រសិទ្ធិស្ត្រី បានបះបោរប្រឆាំងនឹងការរឹតបន្តឹងសង្គម នៅរដ្ឋវិកតូរៀ។ គាត់បានបដិសេធកម្មវិធីសិក្សាតាមបែបប្រពៃណី ដែលកំណត់ដែនជម្រើស និងឱកាសអប់រំស្ត្រី។ គាត់ចង់ឱ្យស្ត្រីមានការអប់រំ ដែលលើកទឹកចិត្តគេឱ្យកំណត់ន័យជីវិតផ្ទាល់ខ្លួន និងជ្រើសរើសមុខរបរផ្ទាល់ខ្លួនរបស់គេ។ គាត់ចង់ឱ្យស្ត្រី ចូលរួមឱ្យបាន*

---

[6] Biographies of Addams are Allen F. Davis, American Heroine: The Life and Legend of Jane Addams (Chicago: Ivan R. Dee, 2000); Gioia Dilbert, A Useful Lady: The Early Life of Jane Addams (New York: Scribner/ Lise Drew, 1999); Barbara G. Polikoff; With One Bold Act: The Story of Jane Addams (Chicago: Boswell Books, 1999); and James W. Linn, Jane Addams: A Biography (Urbana and Chicago: University of Illinois Press, 2000).

[7] Jane Addams, Democracy and Social Ethics (New York: Macmillan, 1905), pp. 178-181.

[8] Jane Addams, Democracy and Social Ethics (New York: Macmillan, 1909), pp.98-103.

ពេញលេញក្នុង នយោបាយ និងសង្គម និងធ្វើការងារ សម្រាប់កំណែទម្រង់ ដូចជាការបញ្ចប់ពលកម្មកុមារ និងនាំមកនូវសន្តិភាព ពិភពលោក[9]។

**គ-ការអប់រំបែបពហុមុខងារ**

**ការអប់រំ និងការសិក្សា** ការអប់រំតាមបែបសង្គមនីយកម្មរបស់ លោកស្រី អាដាំស៍ ដែលទទួលបានឥទ្ធិពលដោយការអភិវឌ្ឍនិយម និងប្រតិបត្តិនិយមនោះ បានស្វែងរកគំនិត ដើម្បីស្តារសុកនិច្ឆ័យសហគមន៍ នៅពេលដែលប្រទេសអាម៉េរិក បានឆ្លងកាត់អន្តរកម្មដ៏ជ្រាលជ្រៅ ពីសង្គមឧស្សាហកម្មទីក្រុងទៅជនបទ។ គាត់ជឿជាក់ថា ការអប់រំ គួរមានលក្ខណៈពហុមុខងារ។ សាលារៀនក្នុងនាមជាភ្នាក់ងារសហគមន៍ ត្រូវបានផ្សារភ្ជាប់ទៅនឹងភ្នាក់ងារសហគមន៍ មួយផ្សេងទៀត ដែលបានឧទ្ទិសដល់ការងារសង្គមផ្ទះដែលជាលំនៅដ្ឋាន។ ដូចគ្នានេះដែរ គ្រូបង្រៀនត្រូវផ្សារភ្ជាប់ទៅនឹងសង្គម។ លោកស្រីអាដាំស៍  ជឿជាក់ថា សាលារៀន អាចមានលក្ខណៈពហុមុខងារ ក្រោយពេលមានការកែទម្រង់តាមបែបអភិវឌ្ឍ ដែលត្រូវបានកាត់បន្ថយគំលាតរបស់ពួកគេពីសង្គម។ កម្មវិធីសិក្សា គួរតែផ្តល់បទពិសោធទូលំទូលាយ ដែលបានស្រាវជ្រាវរុករកបរិស្ថានរបស់កុមារ តាមរបៀបមួយ ដែលបានលើកយកគោលសំខាន់នូវការផ្សារភ្ជាប់គ្នា រវាងជាមួយសង្គមមួយដែលប្រកបទៅដោយបច្ចេកវិទ្យា។

**ឥទ្ធិពលនៅលើការប្រតិបត្តិអប់រំនាពេលសព្វថ្ងៃ** ទស្សនវិជ្ជារបស់លោកស្រីអាដាំស៍ មានសារៈសំខាន់ខ្លាំងណាស់ស ម្រាប់ការអប់រំនាពេលបច្ចុប្បន្ននេះ។ ជំនឿរបស់គាត់ដែលថា ការអប់រំ ត្រូវតែបានរួចចាកផុតពីភាពលំអៀងខាងសមធម៌ភេទ មានទំនាក់ទំនងជាមួយគោលដៅនៃការអប់រំស្ត្រីនាសម័យទំនើបជាពិសេស សិទ្ធិសម ភាពសម្រាប់ស្ត្រី និងសេរីភាពរបស់ពួកគេដើម្បីកំណត់ជីវិត និងជ្រើសរើសមុខរបររបស់ពួកគេ។ ជំនឿរបស់គាត់ដែលថា ឧស្សាហកម្មនិយម គួរតែមានបញ្ចូលគោលបំណងសង្គមដ៏ទូលំទូលាយ ដែលអាចត្រូវបានអនុវត្ត ចំពោះការអះអាងដែលថា បច្ចេកវិទ្យា គួរតែជំរុញដល់ទំនាក់ទំនងដ៏ធំធេង និងការបែងចែក ជាជាងបង្កើតសម្ភារនិយម ដែលតម្រង់ទិសដល់អ្នកប្រើប្រាស់។ បូជនីយកិច្ចរបស់គាត់ក្នុងចលនាសន្តិភាពរបស់ស្ត្រីសម្រាប់ពិភពលោកដោយគ្មានសង្គ្រាម ផ្តល់នូវសារដ៏ចាំបាច់សម្រាប់ពិភពលោកមួយដែលមានការបែកបាក់ខ្ទេចខ្ទីដោយអំពើហិង្សា និងភេរវកម្ម (Violence and terrorism)។

[9] Jane Addams, Emily G. Balch, and Alice Hamilton, *Women at the Hague: The International Congress of Women and its Results* (Urbana and Chicago: The University of Illinois Press, 2002).

## សន្និដ្ឋាន

*ជារួមមក លោកស្រី អាដាំស៍ ផ្តល់ទស្សនវិជ្ជាអប់រំថា ការអប់រំគួរតែជាដំណើរការផ្លាស់ប្តូរ រួមបញ្ចូល និងផ្តោតលើសហគមន៍ដែលជំរុញទំនួលខុសត្រូវសង្គម ការយល់ដឹងអំពីវប្បធម៌ និងការចូលរួមតាមលទ្ធិប្រជាធិបតេយ្យ។ តួនាទីនៃការអប់រំក្នុងការដោះស្រាយបញ្ហាប្រឈមសង្គម និងធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិតសម្រាប់បុគ្គលទាំងអស់។ មូលដ្ឋានគ្រឹះសម្រាប់ការអប់រំសហគមន៍ទំនើប និងបន្តបំផុសគំនិតដល់ការអនុវត្តអប់រំដែលផ្តោតលើយុត្តិធម៌សង្គម។*

## ឯកសារយោង


1-Jay Martin, *The Education of John Dewey: A. Biography*, New York: Columbia University Press, 2002.

2-Walter Feinberg, *"Dewey and Democracy: At the Dawn of the Twenty-first Century," Educational Theory,* Spring 1993.

3-Louis Menard, *The Metaphysical Club: The Story of Ideas in America*, New York: Farrar, Straus and Girous, 2001.

4-Sandra Rosenthal, *Democracy and Education: A Deweyan Approach," Educational Theory*, Fall 1993,

5-John Dewy, *Democracy and Education*, New York: Macmillan, 1916.

6-Matt Parmental,''*The Structure of Dewey's Scientific Ethics''* ,2000.

7- Urbana: *Philosophy of Education Society*, University of Illinois at Urbana-Champaign,2000.

8-Allen F. Davis, *American Heroine: The Life and Legend of Jane Addams,* Chicago: Ivan R. Dee, 2000.

9-Gioia Dilbert, *A Useful Lady: The Early Life of Jane Addams*, New York: Scribner/ Lise Drew, 1999.

10-Barbara G. Polikoff; *With One Bold Act: The Story of Jane Addams*, Chicago: Boswell Books, 1999.

9-James W. Linn, *Jane Addams: A Biography,* Urbana and Chicago: University of Illinois Press, 2000.

11-Jane Addams, *Democracy and Social Ethics*, New York: Macmillan, 1905.

12-Jane Addams, *Democracy and Social Ethics*, New York: Macmillan, 1909.

13-Jane Addams, Emily G. Balch, and Alice Hamilton, *Women at the Hague: The International Congress of Women and its Results*, Urbana and Chicago: The University of Illinois Press, 2002.

14-Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 2020.

15-Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 2023.